អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៧

# សេចក្តីប្រកាសព័ត៌មាន

## អង្គជំនុំជម្រះសាលាដំបូងសម្រេចពន្យារពេលវេលាមួយសប្តាហ៍បន្ថែមទៀតសម្រាប់ការដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល ជាលាយលក្ខណ៍អក្សរ និងកំណត់កាលបរិច្ឆេទជាថ្មីសម្រាប់ការធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់លើសំណុំរឿង០០២/០២

អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានសម្រេចយល់ព្រមមួយផ្នែកតាមការស្នើសុំរបស់ភាគី ដោយពន្យារពេលសម្រាប់ការដាក់សារណាបិទបញ្ចប់កិច្ចពិភាក្សាដេញដោលលើសំណុំរឿង ០០២/០២ ប្រឆាំងនឹង ខៀវ សំផន និង នួន ជា និងកែសម្រួលកាលបរិច្ឆេទសម្រាប់ការធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់បិទបញ្ចប់កិច្ចពិភាក្សាដេញដោល។ ការដាក់សារណាបិទបញ្ចប់កិច្ចពិភាក្សាដេញដោលជាលាយលក្ខណ៍អក្សរ ដែលដំបូងឡើយ ត្រូវបានកំណត់កាលបរិច្ឆេទឲ្យដាក់នៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៧ ឥឡូវនេះ ត្រូវបានពន្យារទៅថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៧ វិញ។ ការពន្យារពេលនេះត្រូវបានសម្រេចធ្វើឡើង ដោយផ្អែកលើដំណើរការនៃការធ្វើកំណែ និងការបញ្ចប់ប្រតិចារឹកសវនាការជាច្រើន ដែលកំពុងរៀបចំដោយអង្គភាពប្រតិចារឹក។

សេចក្តីសន្និដ្ឋានផ្ទាល់មាត់បិទបញ្ចប់កិច្ចពិភាក្សាដេញដោលលើសំណុំរឿង ០០២/០២ ដែលពីមុន កំណត់ថានឹងចាប់ផ្តើមធ្វើនៅថ្ងៃទី ០៥ ខែ មិថុនា ពេលនេះត្រូវបានកំណត់កាលបរិច្ឆេទឡើងវិញ ដោយចាប់ផ្តើមធ្វើនៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៧។ ការផ្លាស់ប្តូរនេះមានភាពចាំបាច់ដើម្បីគោរពសិទ្ធិរបស់ភាគីក្នុងការរៀបចំ និងបង្ហាញនូវទឡ្ហីករណ៍របស់ខ្លួន ក៏ដូចជាដើម្បីធានាថាដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ នឹងត្រូវបញ្ចប់តាមពេលវេលាកំណត់។ នៅក្រោយពេលប្រតិចារឹកសវនាការត្រូវបានកែសម្រួលរួចរាល់ហើយនោះ ភាគីទាំងអស់នឹងត្រូវបានផ្តល់ឱកាសឲ្យដាក់សេចក្តីសន្និដ្ឋានជា

លាយលក្ខណ៍អក្សរបិទបញ្ចប់កិច្ចពិភាក្សាដេញដោលដែលបានកែតម្រូវ ទៅលើកំហុសឆ្គងដែលកើតចេញពីសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរដើមរបស់ពួកគេ។

សេចក្ដីសន្និដ្ឋានផ្ទាល់មាត់បិទបញ្ចប់កិច្ចពិភាក្សាដេញដោលនឹងប្រព្រឹត្តទៅ ចាប់ពីថ្ងៃទី ១៣ ដល់ថ្ងៃទី ២២ ខែ មិថុនា ដូចមានកំណត់ខាងក្រោម៖

- សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៧ (១ថ្ងៃ)
- សហព្រះរាជអាជ្ញា ថ្ងៃទី ១៤-១៥ ខែ មិថុនា ឆ្នាំ ២០១៧ (២ថ្ងៃ)
- ក្រុមមេធាវីការពារក្ដី ថ្ងៃទី ១៦,១៩-២០ខែ មិថុនា ឆ្នាំ ២០១៧ (៣ថ្ងៃ)
- ការធ្វើសេចក្ដីសន្និដ្ឋានតប ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៧ (១ថ្ងៃ)
- ការធ្វើសេចក្ដីសន្និដ្ឋានចុងក្រោយរបស់ជនជាប់ចោទ ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៧ (៤ម៉ោង)

អង្គជំនុំជម្រះសាលាដំបូងនឹងចេញសាលក្រមលើសំណុំរឿង ០០២/០២ នៅក្នុងពេលពេលវេលាសមស្របខាងមុខ បន្ទាប់ពីការធ្វើសេចក្ដីសន្និដ្ឋានផ្ទាល់មាត់បិទបញ្ចប់កិច្ចពិភាក្សាដេញដោល។

*ចំពោះព័ត៌មានបន្ថែមទៀត សូមទាក់ទង៖*


**លោកស្រី ហាយ៉ាត់ អាប៊ូ-សាឡេស**
មន្ត្រីព័ត៌មានសាធារណៈ
ទូរសព្ទដៃលេខ៖ +៨៥៥ (០)១២ ៤៨៨ ៩៣៦
សារអេឡិចត្រូនិក៖ abusaleh@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្ដីខ្មែរក្រហម
ទូរសព្ទដៃលេខ៖ +៨៥៥ (០)១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិក៖ neth.pheaktra@eccc.gov.kh